**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ៣០៩ ទស.ជណ អគឧ

ថ្ងៃសុក្រ ១៤ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

យោងតាមសេចក្តីប្រកាសព័ត៌មានលេខ ១២២ សខល ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ស្តីពីវិធានការកែតម្រូវសម្រាប់សម្រួលដល់អ្នកដំណើរជាពលរដ្ឋខ្មែរកាន់លិខិតឆ្លងដែនបរទេសចូលមកកម្ពុជា ការធ្វើចត្តាឡីស័កសម្រាប់មន្ត្រីការទូត និងមន្ត្រីអង្គការអន្តរជាតិដែលមានទិដ្ឋាការប្រភេទ A និង B និងសេចក្តីជូនដំណឹងរបស់ក្រសួងទេសចរណ៍លេខ ២៥៨សជណ.អគឧ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនដំណឹងដល់**ទេសចរជាតិ-អន្តរជាតិ និងសមាគមឧស្សាហកម្មទេសចរណ៍ទាំងអស់** មេត្តាជ្រាបដូចខាងក្រោម៖

១. ត្រូវបានលើកលែងការតម្រូវឱ្យមានការធានារ៉ាប់រងសុខភាព (Health Insurance) និងការតម្កល់ប្រាក់ចំនួន៣.០០០ដុល្លារអាមេរិក សម្រាប់សេវាផ្សេងៗក្នុងការធ្វើតេស្ត ការធ្វើចត្តាឡីស័ក និងពិនិត្យព្យាបាលជំងឺកូវីដ-១៩ ចំពោះ**អ្នកដំណើរជាពលរដ្ឋខ្មែរកាន់លិខិតឆ្លងដែនបរទេសដែលមានទិដ្ឋាការពិសេស** (ប្រភេទ Visa K) ចូលមកកម្ពុជា ប៉ុន្តែ តម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់សុខភាព (Health Certificate for COVID-19 Free) ដែលចេញដោយអាជ្ញាធរសុខាភិបាល ទទួលស្គាល់ដោយប្រទេសសាមី បញ្ជាក់ថាគ្មានវីរុសកូវីដ-១៩ និងមានសុពលភាព**៧២ម៉ោង** គិតចាប់ពីពេលចេញដំណើរពីប្រទេសតាំងនៅ។

២. ស្ថានបេសកកម្មបរទេស និងអង្គការអន្តរជាតិនៅភ្នំពេញទាំងអស់ ដែលមានអ្នកការទូត និងមន្ត្រីអង្គការអន្តរជាតិដែលកាន់ទិដ្ឋាការប្រភេទ A ឬ B ចូលមកកម្ពុជា ត្រូវអះអាងពីភាពអវិជ្ជមានជំងឺកូវីដ-១៩ របស់អ្នកការទូត និងមន្ត្រីអង្គការអន្តរជាតិរបស់ខ្លួន និងធានាធ្វើបានត្រឹមត្រូវនូវការដាក់ចត្តាឡីស័កក្នុងរយៈពេល១៤ថ្ងៃដោយខ្លួនឯង។

៣. រាល់វិធានការផ្សេងទៀតដែលមានចែងក្នុងសេចក្តីប្រកាសលេខ១០១ សខល ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់គណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងសេចក្តីជូនដំណឹងរបស់ក្រសួងទេសចរណ៍លេខ២៥៨សជណ.អគឧ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ត្រូវស្ថិតនៅជាធរមានដដែល។

អាស្រ័យហេតុនេះ សូម **ទេសចរជាតិ-អន្តរជាតិ និងសមាគមឧស្សាហកម្មទេសចរណ៍ទាំងអស់** មេត្តាជ្រាប និងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ក្រសួងទេសចរណ៍**

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ +៨៥៥ ២៣ ៨៨៤ ៩៧៤ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

*Unofficial Translation*

# Announcement

With reference to the Announcement № 122 សខល dated 17th June 2020 of The Inter-Ministerial Committee to Combat COVID-19 and the Announcement № 258 សជណ.អគឌ of the Ministry of Tourism of Cambodia dated 1st June 2020, the Ministry of Tourism has the honor to inform national and international tourists, and all tourism associations as follows:

1. Lifted the Health Insurance and the deposit of **3,000 USD** for payment any services during the implementation of health measures for COVID-19 related Test, Quarantine Centre and Treatment Services for Cambodian Travelers holding foreign passport with Visa K entering to Cambodia. Therefore, they are requested to have a Health Certificate for COVID-19 Free issued by the Health Authority accredited by the origin country within 72 hours before departure.
2. All foreign representatives and international organizations which their officials hold Cambodian Diplomatic Visa Type A and Official Visa Type B, please proof that those officials are COVID-19 negative and ensure the14 days of self-quarantined.
3. All measures stated in the Notice № 101 សខល dated 20th May 2020 of The Inter-Ministerial Committee to Combat COVID-19 and the Announcement of the Ministry of Tourism № 258 សជណ.អគឌ dated 1st June 2020 is still in effect.

Please national and international tourists, and all tourism associations be informed and take part in the implementation of the above-mentioned measures of this announcement effectively.

**Ministry of Tourism**